ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤៩ អយក.សវណ

សេចក្តីណែនាំ
ស្តីពី
ការអភិវឌ្ឍសមត្ថភាពវិធីសាស្ត្របង្រៀនកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យា ថ្នាក់ដំបូងសម្រាប់គ្រូបង្រៀនបឋមសិក្សា តាមថ្នាលអភិវឌ្ឍសមត្ថភាព (CDP)

ការសិក្សានៅកម្រិតថ្នាក់ដំបូងនៃការអប់រំបឋមសិក្សា ជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ សម្រាប់ការបន្តការសិក្សានៅកម្រិតថ្នាក់បន្តបន្ទាប់ និងមុខវិជ្ជាជំទៃទៀត។ នៅកម្រិតថ្នាក់ដំបូង សិស្សត្រូវចេះអាន សរសេរ និងគិតលេខឱ្យបានច្បាស់លាស់ តាមរយៈការបង្ហាត់បង្រៀនពីលោកគ្រូ អ្នកគ្រូ និងការជំរុញបន្ថែមពីមាតាបិតា អ្នកអាណាព្យាបាល។ គ្រូបង្រៀនត្រូវទទួលបានការបំប៉នសមត្ថភាព ការចុះជួយគាំទ្រពីទីប្រឹក្សាគរុកោសល្យ ស្តីពីការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗសម្បូរបែបប្រកបដោយសិល្បៈ ជាមួយកញ្ចប់សម្ភារៈសម្រាប់បង្រៀន និងសិស្សានុសិស្សត្រូវមានសម្ភារៈសិក្សាគ្រប់គ្រាន់។ ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន ទាំងគ្រូបង្រៀនក្របខ័ណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា និងគ្រូបង្រៀនផ្អែកលើកិច្ចព្រមព្រៀងការងារ អាចធ្វើឡើងដោយផ្ទាល់ និងតាមអនឡាញដែលមានក្នុងថ្នាលអភិវឌ្ឍសមត្ថភាព (CPD) https://cdp.moeys.gov.kh។

ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ លោកគ្រូ អ្នកគ្រូ បង្រៀនថ្នាក់ទី១ ទី២ និងទី៣ ស្តីពីការចូលរួមវគ្គបំប៉នលើការអនុវត្តវិធីសាស្ត្របង្រៀនកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង តាមអនឡាញ ដូចខាងក្រោម៖

១. គោលបំណង

សេចក្តីណែនាំនេះ មានគោលបំណងដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា តាមប្រព័ន្ធអនឡាញ ក្នុងថ្នាលអភិវឌ្ឍសមត្ថភាព (CDP) អំពីវិធីសាស្ត្របង្រៀននិងរៀនកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស លើសមត្ថភាពអាន សរសេរ និងគិតលេខ។

២. យន្តការនៃការអនុវត្ត

២.១- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

- ចូលរួមផ្សព្វផ្សាយសេចក្តីណែនាំនេះ ដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ ដើម្បីអនុវត្តឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព

- ជំរុញនិងលើកទឹកចិត្ត គ្រូបង្រៀនបឋមសិក្សា ជាពិសេសគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនផ្អែកលើកិច្ចព្រមព្រៀងការងារ ឱ្យចូលរួមវគ្គបំប៉នតាមអនឡាញតាមរយៈថ្នាលអភិវឌ្ឍសមត្ថភាព
- ពិនិត្យតាមដាន និងប្រជុំពិភាក្សាដោះស្រាយបញ្ហាដែលកើតមានឡើង ក្នុងដំណើរការវគ្គ និងរាយការណ៍សុំការគាំទ្របន្ថែម ពីមន្ត្រីបច្ចេកទេសនាយកដ្ឋានបឋមសិក្សា ប្រសិនបើចាំបាច់
- បូកសរុបរបាយការណ៍ពីគ្រប់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ផ្ញើមកនាយកដ្ឋានបឋមសិក្សា ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់។ បន្ទាប់មក នាយកដ្ឋានបឋមសិក្សានឹងបូកសរុបជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យលទ្ធភាពក្នុងការវាយតម្លៃ និងផ្តល់ក្រេឌីតជូនអ្នកសិក្សា ឬជាកម្មវត្ថុសម្រាប់បន្តកិច្ចព្រមព្រៀង/កិច្ចសន្យាការងារ ជាដើម។

២.២- ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

- ប្រជុំផ្សព្វផ្សាយសេចក្តីណែនាំនេះ ដល់គ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ ដើម្បីអនុវត្តឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព
- ជំរុញនិងលើកទឹកចិត្ត គ្រូបង្រៀនបឋមសិក្សា ជាពិសេសគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនផ្អែកលើកិច្ចព្រមព្រៀងការងារ នៅតាមគ្រឹះស្ថានបឋមសិក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យចូលរួមវគ្គបំប៉នតាមអនឡាញតាមរយៈថ្នាលអភិវឌ្ឍសមត្ថភាព (CDP)
- ពិនិត្យតាមដាន និងប្រជុំពិភាក្សាដោះស្រាយបញ្ហាដែលកើតមានឡើង ក្នុងដំណើរការវគ្គ និងរាយការណ៍សុំការគាំទ្របន្ថែម ប្រសិនបើចាំបាច់
- បូកសរុបរបាយការណ៍ពីគ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ រួចផ្ញើជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីបូកសរុបជូនក្រសួងអប់រំ យុវជន និងកីឡា។

២.៣- គណៈគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សាសាធារណៈ

- ប្រជុំផ្សព្វផ្សាយសេចក្តីណែនាំនេះ ដល់លោកគ្រូ អ្នកគ្រូ ជាពិសេសគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនផ្អែកលើកិច្ចព្រមព្រៀងការងារ ឱ្យចូលរួមវគ្គបំប៉នតាមអនឡាញតាមរយៈថ្នាលអភិវឌ្ឍសមត្ថភាព (CDP) ទាំងអស់គ្នា ប្រកដោយប្រសិទ្ធភាព
- ជំរុញការអនុវត្ត ពិនិត្យតាមដាន និងប្រជុំពិភាក្សាដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងដំណើរការសិក្សារបស់លោកគ្រូ អ្នកគ្រូ និងរាយការណ៍សុំការគាំទ្របន្ថែម ប្រសិនបើចាំបាច់
- រៀបចំរបាយការណ៍វឌ្ឍនភាព ជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រក្សាទុករាល់ទិន្នន័យ ព័ត៌មាន និងរបាយការណ៍ស្តីពីការចូលរួមវគ្គបំប៉នតាមអនឡាញ ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃការអនុវត្តការងាររបស់គ្រូបង្រៀន។

៣. អ្នកសិក្សា

៣.១- មុនពេលដំណើរការសិក្សា

- គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនផ្អែកលើកិច្ចព្រមព្រៀងការងារ និងគ្រូបង្រៀនក្របខ័ណ្ឌដែលកំពុងបង្រៀនថ្នាក់ទី១ ទី២ និងទី៣ និងគ្រូបង្រៀនកម្រិតថ្នាក់ផ្សេងទៀត នៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ អាចចុះឈ្មោះចូលរៀនវគ្គសិក្សាអនឡាញស្តីពីវិធីសាស្ត្របង្រៀន និងរៀនកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង តាមថ្នាលអភិវឌ្ឍសមត្ថភាព (CDP) ទៅតាមគោលការណ៍ណែនាំ

- អ្នកសិក្សាត្រូវបង្កើតគណនីថ្នាលអភិវឌ្ឍសមត្ថភាព (CDP) ដោយមើលវីដេអូណែនាំ តាមរយៈតំណភ្ជាប់ និង QR Code នៅក្នុងឧបសម្ព័ន្ធជូនភ្ជាប់
- អ្នកសិក្សាត្រូវចុះឈ្មោះចូលរៀនក្នុងវគ្គសិក្សាអនឡាញស្តីពីវិធីសាស្ត្របង្រៀន និងរៀនកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង នៅតាមរាជធានី ខេត្ត ដែលកំពុងបម្រើការងារ ដោយប្រើលេខកូដ ដែលមាននៅក្នុងឧបសម្ព័ន្ធជូនភ្ជាប់
- អ្នកសិក្សាត្រូវឈ្វេងយល់អំពីថ្នាលអភិវឌ្ឍសមត្ថភាព (CDP) ក្នុងវីដេអូណែនាំ តាមរយៈតំណភ្ជាប់ និង QR Code នៅក្នុងឧបសម្ព័ន្ធជូនភ្ជាប់
- អ្នកសិក្សាត្រូវចូលរួមក្នុងក្រុមតេលេក្រាម តាមរយៈតំណភ្ជាប់ និង QR Code នៅក្នុងឧបសម្ព័ន្ធជូនភ្ជាប់ ដើម្បីទទួលបានព័ត៌មាន និងការគាំទ្រផ្សេងៗទាក់ទងនឹងការសិក្សា
- អ្នកសិក្សាត្រូវមានឧបករណ៍អេឡិចត្រូនិក ដូចជាទូរសព្ទឆ្លាតវៃ/ថេប្លេត/កុំព្យូទ័រយួរដៃ/កុំព្យូទ័រលើតុ និងមានសេវាអ៊ីនធើណិត សម្រាប់ប្រើប្រាស់ក្នុងការសិក្សា។

៣.២- រំឭកពេលដំណើរការសិក្សា

- រយៈពេលសិក្សា មានរយៈពេលប្រមាណ ១ខែ សម្រាប់មួយមុខវិជ្ជា និងមួយកម្រិតថ្នាក់។ អ្នកសិក្សាត្រូវចូលរៀនចន្លោះពី ៣០នាទី ទៅ ៦០នាទី ជាមធ្យម ក្នុងមួយថ្ងៃ ទៅតាមលទ្ធភាពសមស្របដែលអាចធ្វើបាន
- អ្នកសិក្សាត្រូវចូលរួមធ្វើតេស្តមុនវគ្គសិក្សាស្តីពីកញ្ចប់សម្ភារៈអំណាន ឬ គណិតវិទ្យា ថ្នាក់ទី១ និង/ឬ ទី២ និង/ឬ ទី៣ តាមរយៈតំណភ្ជាប់នៅលើថ្នាលអភិវឌ្ឍសមត្ថភាព (CDP)
- ពេលធ្វើតេស្តមុនវគ្គសិក្សាចប់ អ្នកសិក្សាត្រូវចូលរៀនខ្លឹមសារតាមផ្នែកនីមួយៗ ដែលមាន ៤ផ្នែក និងឆ្លើយសំណួរទៅតាមផ្នែកនីមួយៗដែលមាននៅក្នុងមេរៀនឱ្យបានត្រឹមត្រូវ។ អ្នកសិក្សាត្រូវបញ្ចប់ទៅតាមផ្នែកនីមួយៗ តាមលំដាប់លំដោយ ដោយមិនអាចរំលងផ្នែកណាមួយឡើយ។ ប្រសិនបើអ្នកសិក្សាបានបញ្ចប់ផ្នែកទី១ បានពេញលេញ អ្នកសិក្សានឹងអាចបន្តរៀនផ្នែកទី២ នាពេលបន្តបន្ទាប់ទៀតបានដោយស្វ័យប្រវត្តិ និងបន្តផ្នែកទី៣ និងទី៤ រហូតដល់ចប់
- អ្នកសិក្សាត្រូវពិនិត្យវឌ្ឍនភាពនៃការសិក្សារបស់ខ្លួនជាប្រចាំ ដែលមាននៅលើថ្នាលសិក្សា ដើម្បីត្រៀមបន្តរៀននៅថ្ងៃបន្ទាប់។

បញ្ជាក់៖ អ្នកសិក្សា ត្រូវធ្វើតេស្តបញ្ចប់វគ្គសិក្សា នៅពេលបញ្ចប់ការរៀនគ្រប់ទាំង ៤ផ្នែក។

៣.៣- ក្រោយពេលដំណើរការសិក្សា

- អ្នកសិក្សាត្រូវទាញយកវិញ្ញាបនបត្របញ្ជាក់ការសិក្សាតាមថ្នាលអភិវឌ្ឍសមត្ថភាព។ អ្នកសិក្សាអាចទាញយកវិញ្ញាបនបត្រនេះបាន លុះត្រាតែសម្រេចបានវឌ្ឍនភាពខ្លឹមសារមេរៀនពេញលេញចាប់ពី ៧០% ឡើងទៅ និងប្រឡងជាប់តេស្តបញ្ចប់វគ្គសិក្សាបានពិន្ទុចាប់ពី ៧០%ឡើងទៅ
- អ្នកសិក្សាត្រូវធ្វើរបាយការណ៍ ដោយភ្ជាប់វិញ្ញាបនបត្រថតចម្លង ផ្ញើជូនគណៈគ្រប់គ្រងសាលារៀន ដើម្បីធ្វើរបាយការណ៍ ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- អ្នកសិក្សាត្រូវយកចំណេះដឹងដែលបានទទួលពីវគ្គសិក្សា ទៅអនុវត្តនៅតាមអង្គភាពរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ដោយមានការចុះជួយគាំទ្រពីទីប្រឹក្សាគរុកោសល្យ ដើម្បីអភិវឌ្ឍសមត្ថភាព

ក្លាយជាគ្រូបង្រៀនដែលបានអនុវត្តវិធីសាស្ត្របង្រៀនកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យា ថ្នាក់ដំបូង យ៉ាងតិចចាប់ពីកម្រិត២ ឡើងទៅ

- អ្នកសិក្សាត្រូវចងក្រងជាសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) តាមកម្រង និងក្នុងក្រុមតេលេក្រាម ដើម្បីចែករំលែកឧត្តមានុវត្តន៍ ចូលរួមដោះស្រាយនូវរាល់បញ្ហាប្រឈមដែលអាចកើតមានឡើង ក្នុងដំណើរការបង្រៀននិងរៀន ឆ្លើយតបទៅនឹងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD)។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រូបង្រៀនក្របខ័ណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា និងគ្រូបង្រៀនផ្អែកលើកិច្ចព្រមព្រៀងការងារ ត្រូវចូលរួមសហការអនុវត្តប្រកបដោយប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ៣ កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

កន្លែងទទួលៈ

- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

- កាលប្បវត្តិ
- ឯកសារ នា.បឋមសិក្សា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ឧបសម្ព័ន្ធ សម្រាប់ការអនុវត្តកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង

ល.រ		វីដេអូណែនាំ	QR Code
១		របៀបបង្កើតណានីថ្នាលអតិវឌ្ឍសមត្ថភាព https://www.youtube.com/watch?v=i_BKmrwP4A8	
២		វីដេអូចុះឈ្មោះចូលរៀនវគ្គសិក្សាដោយប្រើលេខកូដ https://www.youtube.com/watch?v=Ve5i9w3Ndf0&t=3s	
៣		ធនធានឯកសារស្តីពីការប្រើប្រាស់ថ្នាលអតិវឌ្ឍសមត្ថភាព https://cdp.moeys.gov.kh/course/view.php?id=3	
៤		ក្រុមគេលេក្រាម សម្រាប់អ្នកសិក្សាទទួលបានព័ត៌មាន និងគាំទ្រផ្សេងៗអំពីវគ្គសិក្សា https://t.me/+QOt96DUht3Y0YmM1	

៤. លេខកូដចុះឈ្មោះចូលរួមវគ្គសិក្សានៅតាមរាជធានី ខេត្ត

ល.រ	ឈ្មោះរាជធានី ខេត្ត	លេខកូដថ្នាក់ទី១	លេខកូដថ្នាក់ទី២	លេខកូដថ្នាក់ទី៣
១	ភ្នំពេញ	5c3eje	t4xvg6	9j4m2v
២	បាត់ដំបង	eeuy8u	28vhws	nxdyt7
៣	កំពង់ចាម	xm4anv	2pcrd9	9ekgmx
៤	កំពង់ឆ្នាំង	vkcchz	hf6exj	xynthq
៥	កំពង់ស្ពឺ	nr3uf9	uf49ah	kmreqw
៦	កំពត	df6ss7	c89bii	nnjjf6
៧	កែប	nfdzpe	8bf6hh	prsw5i
៨	កោះកុង	2zk9j4	r45k7x	pkpr9b
៩	ឧត្តរមានជ័យ	z85hba	uy23h3	mpgeyv
១០	ប៉ៃលិន	z54ika	jxzazu	uhf8in
១១	ព្រះវិហារ	feg5jt	kwcm5v	agxnws
១២	ពោធិ៍សាត់	9syb4k	zf2yuc	hhvpke
១៣	រតនគិរី	ykqsgq	dysz2g	tbwmuh
១៤	សៀមរាប	5wwix3	n5bnr6	bc8uti
១៥	ស្ទឹងត្រែង	4gwuef	bzbwuq	6kh6z5
១៦	ស្វាយរៀង	x4utw2	7m2tru	zw2f97
១៧	តាកែវ	t2fwg4	txiuyy	7sbi54
១៨	ត្បូងឃ្មុំ	kk95s4	69a9n3	upg2pe
១៩	កំពង់ធំ	itjxvw	7p2cip	29ngd3
២០	កណ្តាល	ums6a5	p7wq6q	vyskfw
២១	ក្រចេះ	ma5y4d	u7nk4a	dewkzj
២២	មណ្ឌលគិរី	svf8qh	9euhy2	bwf3j8
២៣	ព្រះសីហនុ	694jru	3fd3rp	2rbiky
២៤	បន្ទាយមានជ័យ	8sdvg6	8q5gph	mc8gt2
២៥	ព្រៃវែង	6bkv54	mmuee4	3imaiu